








ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# វិធីបង្រៀន

# សិទ្ធិកុមារ

## ក្នុងមុខវិជ្ជាសិក្សាសង្គម

## ថ្នាក់ទី១.២.៣.៤.៥ និងទី៦

ផលិតដោយ: នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ សហការជាមួយ:

មូលនិធិសិទ្ធិកុមារ
Child Rights Foundation

# សេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និង កីឡា

ឯកសារស្តីពីវិធីបញ្ជ្រាបសិទ្ធិកុមារក្នុងមុខវិជ្ជាសិក្សាសង្គមសម្រាប់សិស្សសាលាបឋមសិក្សាពីថ្នាក់ទី ១ ដល់ទី៦ នេះគឺជាជំនួយសម្រាប់លោកគ្រូ អ្នកគ្រូដែលមានតួនាទីយ៉ាងសំខាន់ក្នុងការបង្រៀនកុមារឱ្យបាន យល់ដឹងអំពីខ្លឹមសារនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ។

កុមារគឺជាក្រុមមួយដែលមានតម្លៃបំផុតសម្រាប់សង្គមជាតិនីមួយៗ ។ ដូច្នេះកុមារចាំបាច់ត្រូវតែបាន យល់ជ្រួតជ្រាបអំពីសិទ្ធិទាំងឡាយដែលខ្លួនមាន អ្វីជាផលប្រយោជន៍ដែលខ្លួនត្រូវទទួលបាន ការការពារ ពិសេសអ្វីខ្លះដែលគេត្រូវទទួលបានពីមនុស្សធំ មនុស្សចាស់ដែលនៅជុំវិញខ្លួនគេ និងការទទួលខុសត្រូវរបស់ ពួកគេ ចំពោះខ្លួនឯង ក្រុមគ្រួសារ សាលារៀន និងសង្គម ។

តាមរយៈឯកសារនេះលោកគ្រូ អ្នកគ្រូនឹងបានស្វែងយល់អំពីវិធីសាស្ត្រខ្លះៗក្នុងការបញ្ជ្រាបអនុសញ្ញា ស្តីពីសិទ្ធិកុមារទៅតាមមុខវិជ្ជាសិក្សាសង្គម ហើយក៏មានលើកយកមេរៀនចំនួន៤ សម្រាប់កម្រិតថ្នាក់នីមួយៗ មកធ្វើជាឧទាហរណ៍ ព្រមទាំងមានកិច្ចតែងការបង្រៀនជាលំនាំសម្រាប់ការត្រៀមរៀបចំបង្រៀនមួយចំនួន ទៀតផង ។

ក្រសួងសង្ឃឹមថាលោកគ្រូ អ្នកគ្រូ នឹងខិតខំយកចិត្តទុកដាក់ប្រើប្រាស់សៀវភៅនេះជាឯកសារជំនួយ ក្នុងការបញ្ជ្រាបសិទ្ធិកុមារឱ្យបានទូលំទូលាយទៅដល់ស្រទាប់សិស្ស និងពង្រីកការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិ កុមារនេះនៅតាមមូលដ្ឋានប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ ។

ភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០០៦

ជ.ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

ប៉ុក_ថន

# អារម្ភកថា

សៀវភៅ "វិធីបញ្ជ្រាបសិទ្ធិកុមារ" នេះត្រូវបានរៀបចំឡើង ដោយអង្គការមូលនិធិសិទ្ធិកុមារ ( មសក) សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីជាជំនួយស្មារតីចំពោះលោកគ្រូ អ្នកគ្រូនៅតាមសាលាបឋមសិក្សានានា ដែលកំពុងត្រូវការឧបករណ៍នេះ ដើម្បីលើកកម្ពស់ការផ្សព្វផ្សាយអំពីសិទ្ធិកុមារទៅដល់សិស្សានុសិស្ស ឱ្យកាន់តែមានប្រសិទ្ធភាព ។

កន្លងមក មូលនិធិសិទ្ធិកុមារ បានរួមសហការជាមួយនាយកដ្ឋានយុវជន និងនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ នៃក្រសួងអប់រំ យុវជន និងកីឡា បានចងក្រងឯកសារសម្រាប់អ្នកអប់រំបន្តស្តីអំពី "សិទ្ធិ និងការទទួលខុសត្រូវរបស់កុមារនិងយុវជន" និងសៀវភៅបង្រៀនអំពី "សិទ្ធិកុមារ" សម្រាប់គ្រូឧទ្ទេសនៃសាលាគរុកោសល្យ និងវិក្រឹតការខេត្ត និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគរួចមកហើយ ប៉ុន្តែលោកគ្រូ អ្នកគ្រូដែលបង្រៀនសិស្សនៅបឋមសិក្សាបានសំណូមពរឱ្យរៀបចំចងក្រងអំពីវិធីបញ្ជ្រាបនេះបន្ថែមទៀត ដើម្បីងាយស្រួលយកទៅប្រើប្រាស់ផ្ទាល់ជាមួយសិស្ស ។

សៀវភៅនេះបានលើកឡើងអំពីវិធីបញ្ជ្រាបសិទ្ធិកុមារ តាមរយៈមុខវិជ្ជាសិក្សាសង្គម សម្រាប់សិស្សពីថ្នាក់ទី ១ ដល់ទី ៦ ដោយផ្អែកទៅតាមសៀវភៅសិស្ស សៀវភៅគ្រូ នៃកម្មវិធីសិក្សារបស់ក្រសួង អប់រំ យុវជន និង កីឡា ផ្នែកបឋមសិក្សា ។ ខ្លឹមសារដែលមាននៅក្នុងសៀវភៅនេះ គឺគ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ ដែលលោកគ្រូ អ្នកគ្រូអាចច្នៃប្រឌិត និងកែលំអថែមទៀត ទៅតាមលទ្ធភាព និងពេលវេលាជាក់ស្តែង ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះលោក លោកស្រីដែលជាសិក្ខាកាមនៃវគ្គបំប៉នគ្រូបង្គោលស្តីអំពីការបញ្ជ្រាបសិទ្ធិកុមារទៅក្នុងមុខវិជ្ជាសិក្សាសង្គម ដែលបានរួមចំណែកចងក្រងសៀវនេះឡើង ។

យើងខ្ញុំសង្ឃឹមថាសៀវភៅនេះនឹងជួយរួមចំណែកផ្តល់ចំពោះលោកគ្រូ អ្នកគ្រូនូវចំណេះដឹង និងទេពកោសល្យថ្មី សម្រាប់ការផ្សព្វផ្សាយអំពីសិទ្ធិកុមារទៅដល់សិស្សប្រកបដោយគុណភាព និងប្រសិទ្ធភាព ។ យើងខ្ញុំរីករាយ និងសូមស្វាគមន៍ចំពោះមតិកែលំអពីលោក លោកស្រី ។

## គណៈកម្មការរៀបចំឯកសារ

| | |
|---|---|
| ១- ឯកឧត្តម ណាត ប៊ុនរឿន | ៦- លោក មួង ចាន់ទូច |
| ២- លោក លាង សេងហាក់ | ៧- លោកស្រី នួន នារតី |
| ៣- លោកស្រី ម៉ុម ថានី | ៨- លោក ម៉ៅ ម៉ុក |
| ៤- លោក ជា ផុន | ៩- លោកស្រី វ៉ាណ ម៉ារី |
| ៥- លោក លឹម ប៉េង | ១០- លោក ទី សុវណ្ណារី |

# មាតិកា


| ល.រ | មេរៀន | ខ្លឹមសារបញ្ញាប | ទំព័រ |
|---|---|---|---|
| **សិក្សាសង្គមថ្នាក់ទី១** | | | |
| ១ | មេរៀនទី១៩ "វិន័យសាលារៀន" | សិទ្ធិអភិវឌ្ឍន៏ ( សិទ្ធិទទួលការសិក្សាអប់រំ លេងកម្សាន្ត និងលំហែ) | ១-២ |
| ២ | មេរៀនទី៣៧ "ចំណីអាហារ" | សិទ្ធិរស់រានមានជីវិត ( សិទ្ធិទទួលចំណីអាហារគ្រប់គ្រាន់ សិទ្ធិទទួលការព្យាបាល) | ៣-៤ |
| ៣ | មេរៀនទី៤៩ "សន្តិសុខតាមផ្លូវសាធារណៈ" | សិទ្ធិទទួលការការពារ ( ការពារពីគ្រោះថ្នាក់នានា) | ៥-៦ |
| ៤ | មេរៀនទី៥៨ " តំហែរក្សា" | សិទ្ធិក្នុងការចូលរួម ( សិទ្ធិចូលរួមសកម្មភាពសមស្រប) | ៧-៨ |
| **សិក្សាសង្គមថ្នាក់ទី២** | | | |
| ៥ | មេរៀនទី២៥ "រុយ និងមូស" | សិទ្ធិរស់រានមានជីវិត | ៩-១០ |
| ៦ | មេរៀនទី៣១ "គ្រោះថ្នាក់" | សិទ្ធិទទួលការការពារ ( ការពារពីអំពើរំលោភបំពាននានា) | ១១-១២ |
| ៧ | មេរៀនទី៤១ "តម្លៃការងារ" | សិទ្ធិអភិវឌ្ឍន៏ ( ការសិក្សាអប់រំ) | ១៣ |
| ៨ | មេរៀនទី៥៨ "ការស្រឡាញ់ និងជួយមិត្តភក្តិ" | សិទ្ធិក្នុងការចូលរួម (ចូលរួមបង្កើតជាក្រុម ចូលរួមសកម្មភាពនានា ) | ១៤ |
| **សិក្សាសង្គមថ្នាក់ទី៣** | | | |
| ៩ | មេរៀនទី១ "ការគោរព" | សិទ្ធិទទួលការការពារ ( ការការពារពីការរើសអើងស្ត្រីភេទ និងការពារពីការរើសអើងជនពិការ) | ១៥-១៧ |
| ១០ | មេរៀនទី១៨ "ការសំអាត" | សិទ្ធិរស់រានមានជីវិត "ការថែទាំសុខភាព ចំណីអាហារ និងជម្រក" | ១៨-១៩ |
| ១១ | មេរៀនទី៤១ "ការជួយគ្នា" | សិទ្ធិអភិវឌ្ឍន៏ | ២០ |
| ១២ | មេរៀនទី៤៤ "ការគ្រប់គ្រងថ្នាក់រៀន" | សិទ្ធិក្នុងការចូលរួម | ២១ |

| | | | |
|---|---|---|---|
| **សិក្សាសង្គមថ្នាក់ទី៤** | | | |
| ១៣ | មេរៀនទី១៩ "អនាម័យភូមិស្ថាន" | សិទ្ធិរស់រានមានជីវិត (សិទ្ធិទទួលការព្យាបាល និងថែទាំសុខភាព និងសិទ្ធិមានជម្រកសមរម្យ) | ២២-២៣ |
| ១៤ | មេរៀនទី៤៣ "មាតុភូមិ" | សិទ្ធិក្នុងការការពារ (សិទ្ធិទទួលការការពារពីសង្គ្រាម ឬជម្លោះប្រដាប់អាវុធ) | ២៤-២៥ |
| ១៥ | មេរៀនទី៥៨ "សេចក្តីក្លាហាន" | សិទ្ធិក្នុងការចូលរួម | ២៦ |
| ១៦ | មេរៀនទី៦១ "ថវិកាសាលារៀន" | សិទ្ធិអភិវឌ្ឍន៍ | ២៧-២៨ |
| **សិក្សាសង្គមថ្នាក់ទី៥** | | | |
| ១៧ | មេរៀនទី១ "សណ្តាប់ធ្នាប់ក្នុងផ្ទះបាយ" | សិទ្ធិរស់រានមានជីវិត (ការថែទាំសុខភាព) | ២៩-៣០ |
| ១៨ | មេរៀនទី១៣ "ជម្ងឺអេដស៍" | សិទ្ធិទទួលការការពារ (ការពារពីការរើសអើង) | ៣១ |
| ១៩ | មេរៀនទី១៩ "បញ្ញវន្ត" | សិទ្ធិអភិវឌ្ឍន៍ (សិទ្ធិទទួលការអប់រំ) | ៣២ |
| ២០ | មេរៀនទី៣៤ "សេរីភាព" | សិទ្ធិក្នុងការចូលរួម (សិទ្ធិបញ្ចេញមតិយោបល់) | ៣៣ |
| **សិក្សាសង្គមថ្នាក់ទី៦** | | | |
| ២១ | មេរៀនទី៤ "របៀបការពារជម្ងឺអេដស៍" | សិទ្ធិរស់រានមានជីវិត (ការថែទាំសុខភាព) | ៣៤ |
| ២២ | មេរៀនទី២៥ "ក្រសួងនានា" | សិទ្ធិអភិវឌ្ឍន៍ | ៣៥-៣៦ |
| ២៣ | មេរៀនទី៣៤ "បណ្តាញផ្សព្វផ្សាយព័ត៌មាន" | សិទ្ធិក្នុងការចូលរួម (ចូលរួមផ្សព្វផ្សាយព័ត៌មាន) | ៣៧-៣៨ |
| ២៤ | មេរៀនទី៥៥ "សីលប្រាំ" | សិទ្ធិទទួលការការពារ (ការពារពីការកេងប្រវ័ញ្ចផ្លូវភេទ) | ៣៩ |
| **ឧបសម្ព័ន្ធ** | | | |
| **១. ករណីសិក្សា** | | | |
| **២. ព័ត៌មានសង្ខេបអំពីវិធីបញ្ជ្រាបសិទ្ធិកុមារក្នុងមុខវិជ្ជាសិក្សាសង្គម** | | | |
| **៣. គំរូនៃកិច្ចតែងការបង្រៀន** | | | |

# សិទ្ធិកុមារ




ឧបត្ថម្ភដោយៈ www.kerkinactie.nl